ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ : ១២៥

ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១២

<u>សាលដីកា</u>

លេខ :៤៧៧"ឈ"

ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១២

បានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី១៣ខែវិច្ឆិកា ឆ្នាំ ២០១២ ដោយមានសមាសភាពដូចតទៅ :

-ឯកឧត្តម [redacted] ជាប្រធាន
-លោក ជាចៅក្រម
-លោក ជាចៅក្រម
-លោក ជាចៅក្រម
-លោក ជាចៅក្រម
លោក ជាក្រឡាបញ្ជី

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

-លើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ០៤ក្រ៣"ស" ចុះថ្ងៃទI ២៩ខែកុម្ភៈ ឆ្នាំ២០១២ នៃសំណុំរឿងរដ្ឋប្បវេណីលេខ២២៩ចុះថ្ងៃទី០៨ ខែកក្កដាឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ រវាង :

<u>-ដើមចោទ</u>:-ឈ្មោះ [redacted] ចឹក កេវ ប្រុស ជាតិខ្មែរ"ជាម្ចាស់បណ្តឹងសាទុក្ខ" អាយុ៥៣ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ មានទីលំនៅសព្វថ្ងៃភូមិ-ដងរុនកើត ឃុំបន្ទាយនាង -ស្រុក-ស្រុកមង្គលបូរី ខេត្ត បន្ទាយមានជ័យ។

មានមេធាវីតំណាងដោយអណត្តិឈ្មោះម្លូង សុគន្ធ

-ចុងចម្លើយឈ្មោះ

១-[redacted] លន់ "ជាចុងបណ្តឹងសាទុក្ខ" អាយុ៤៧ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ

២-[redacted] នី"ជាចុងបណ្តឹងសាទុក្ខ" អាយុ៣៧ ឆ្នាំ ជាតិ ខ្មែរ មុខរបរជួសជុលម៉ូតូ . មានទីលំនៅសព្វថ្ងៃភូមិអូរស្ងួន-ឃុំបន្ទាយនាង-ស្រុកមង្គលបូរី ខេត្ត បន្ទាយមានជ័យ។

-២០៣


មហាវិថី សម្តេចសុធារស, សង្កាត់ចតុមុខ, ខណ្ឌដូនពេញ, កម្ពុជា Sothearos Blvd, Sangkat Chatomuk, Khan Daun Penh, Cambodia



Scanned with CamScanner

៣[redacted] ល្ងួន“ជាចុងបណ្តឹង អាយុ ៤១ ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ.
មានទីលំនៅសព្វថ្ងៃភូមិ គោកក្ដួច-ឃុំបន្ទាយនាង-ស្រុកមង្គលបូរី ខេត្ត បន្ទាយមានជ័យ។

**កម្មវត្ថុបណ្តឹង**:ប្តឹងសុំបញ្ជាក់អំពីសិទ្ធិកាន់កាប់និងសុំអោយចុងចម្លើយប្រគល់ដីទំហំ ១រ៉ៃ (៤០គុណ៤០)។

តាមបណ្តឹងសាទុក្ខលេខ១២៨ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] សុគន្ធ ជាមេធាវីតំណាងដោយអណត្តិអោយ [redacted] ចឹក ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ០៤“ក្រពស” ចុះថ្ងៃទី២៩ ខែកុម្ភៈឆ្នាំ២០១២ត្រង់ចំណុចសាលដីកាទាំងមូល។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ១២៥ចុះថ្ងៃទី២៥ខែមិថុនាឆ្នាំ២០១២ របស់តុលាការកំពូល។

តាមពាក្យបណ្តឹងចុះថ្ងៃទី០៩ខែមិថុនាឆ្នាំ២០១១របស់ឈ្មោះ [redacted] ចឹក ថាខ្លួនជាម្ចាស់កម្មសិទ្ធិកាន់កាប់ដីតាំងពីឆ្នាំ១៩៧៩មានការទទួលស្គាល់ពីអាជ្ញាធរភូមិឃុំ ស្រុកហើយខ្លួនបានដាំដំណាំផ្សេងៗលើដីទំហំ១រ៉ៃ៤០មគុណ៤០មស្ថិតនៅភូមិដងរុនលិចឃុំបន្ទាយនាងស្រុកមង្គលបូរីខេត្តបន្ទាយមានជ័យមិនដែលអាក់ខានឡើយដែលមានព្រំប្រទល់ខាងជើងទល់[redacted]វុននិង[redacted]ទីខាងកើតទល់និងប្រឡាយខាងត្បូងទល់និងឈ្មោះ[redacted]ស្លួរខាងលិចទល់និងឈ្មោះ[redacted]មួយ។ស្រាប់តែចុងចម្លើយនាំគ្នារំលោភបំពានលើដីខ្លួនកាប់កាប់ហើយចុងចម្លើយទាំងបីនាក់មិនព្រមប្រគល់ដីអោយខ្លួនវិញឡើយ។

តាមបណ្តឹងតបចុះថ្ងៃទី១៦-០៩-២០១១ ឈ្មោះ [redacted] លន់ [redacted] ល្ហួម និង [redacted] ធី បានបញ្ជាក់ថានៅ១៩៨៨ម្តាយពួកខ្លួនឈ្មោះ[redacted] កើនបានទទួលមរណភាពដោយបន្សល់ទុកដីចំការមួយកន្លែងទំហំ២៨២០ម៉ែត្រការ៉េ ស្ថិតនៅភូមិ ដងរុនលិច ឃុំ បន្ទាយនាងស្រុកមង្គលបូរីខេត្តបន្ទាយមានជ័យមានព្រំប្រទល់ខាងជើងទល់នឹង[redacted]វុន និង [redacted]ទី ខាងកើតទល់ប្រឡាយ ខាងត្បូងទល់នឹងប៊ុនស្លួរខាងលិចទល់នឹងនាង មួយ។មុនពេលម្តាយខ្លួនស្លាប់បានផ្តាំថា“គាត់ជំពាក់លុយគេចំនួន២ម៉ឺនបាតអោយលក់ដីនោះសងគេទៅ “តែដីនោះពុំបានលក់ទេព្រោះឈ្មោះ [redacted] ល្ហួមបានទៅស៊ីឈ្នួលគេយកលុយសងម្ចាស់បំណុល។ ដីទំនាស់គឺជាដីកេរ្តិ៍ម្តាយខ្លួនមានលិខិតបញ្ជាក់របស់អាជ្ញាធរដែនដីពុំមែនជាដីចំការរបស់[redacted]ចឹកទេ ពួកខ្លួនបានអោយគុជ ចឹក បង្កបង្កើនផលជាបណ្តោះអាសន្នប៉ុណ្ណោះ។

-បានឃើញសាលក្រមរដ្ឋប្បវេណីលេខ០៥“គ” ចុះថ្ងៃទី០៤ ខែមិនាឆ្នាំ២០១១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ច្រានចោលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ [redacted] ចឹក ចុះថ្ងៃទី០៩ខែមិថុនាឆ្នាំ២០១០

២-ទទួលស្គាល់ពាក្យបណ្តឹងតបរបស់ចុងចម្លើយឈ្មោះ [redacted] លន់ ឈ្មោះ [redacted] ល្ហួម និងឈ្មោះ [redacted] ធី ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ។



Scanned with CamScanner

61/3

៣-ប្រគល់សិទ្ធិកាន់កាប់ដីចំការមួយកន្លែងទំហំ២៨២០ម៉ែត្រការ៉េ ស្ថិតនៅភូមិអង្គរទលិចឃុំបន្ទាយនាងស្រុកមង្គលបូរីខេត្តបន្ទាយមានជ័យ មានព្រំប្រទល់ខាងជើងទល់នឹងឃាយរុននិងគ្រូទី ខាងកើតទល់នឹងប្រឡាយ ខាងត្បូងទល់នឹងឈ្មោះ [redacted] សួរ និង ខាងលិចទល់នឹងនាង មួយ អោយទៅចុងចម្លើយឈ្មោះ [redacted] លន់ ភេទស្រី [redacted] លួម ភេទស្រី និងឈ្មោះ [redacted] ធី ភេទប្រុស ដើម្បីបែងចែកជាបីចំណែកស្មើគ្នា ។

៤-សាលក្រមនេះប្រកាសជាសាធារណៈ:

ចំពោះមុខដើមចោទនិងចុងចម្លើយបើភាគីណាមិនសុខចិត្តមានសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញបណ្ដឹងឧទ្ធរណ៍លេខ០៩ចុះថ្ងៃទី១០ ខែមិនា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ចឹក ប្ដឹងមិនសុខចិត្តនឹងសាលក្រមលេខ០៥"គ"ចុះថ្ងៃទី០៨ខែមិនាឆ្នាំ២០១១របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុចសាលក្រមទាំងមូល។

-បានឃើញសាលដីការដ្ឋប្បវេណីលេខ០៤"ក្រ៣ស" ចុះថ្ងៃទី២៩ ខែមិនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលបណ្ដឹងឧទ្ធរណ៍លេខ០៩ចុះថ្ងៃទី១០ខែមិនាឆ្នាំ២០១១របស់ឈ្មោះគុជចឹក ជាដើមចោទទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែច្រានចោលដោយផ្ទុយនិងគតិច្បាប់។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ០៥ " គ " ចុះថ្ងៃទី០៨ ខែមិនាឆ្នាំ២០១១របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ទុកជាបានការពេញទាំងមូល។

៣-ប្រាក់ប្រដាប់ក្ដីជាបន្ទុកលើដើមចោទ។

សាលដីកានេះទាញហេតុផលផ្ទាល់មាត់ជាសាធារណៈនៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២ ប្រកាសជាសាធារណៈនៅថ្ងៃទី២៩ខែកុម្ភៈឆ្នាំ២០១២បើកផ្លូវសាទុក្ខ០១ខែគិតពីថ្ងៃបានទទួលសាលដីកានេះ។

តាមបណ្ដឹងសាទុក្ខលេខ១២៨ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] សុគុន្ធ ជាមេធាវីតំណាងដោយអាណត្តិអោយ [redacted] ចឹក ប្ដឹងមិនសុខចិត្តនឹងសាលដីកាលេខ០៤"ក្រ៣ស" ចុះថ្ងៃទី២៩ ខែកុម្ភៈឆ្នាំ២០១២ត្រង់ចំណុចសាលដីកាទាំងមូល។

-បានឃើញលិខិតបញ្ជាក់អំពីមូលហេតុបណ្ដឹងសាទុក្ខ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ចឹក ។

-បានឃើញលិខិតដាក់ឯកសារត្រៀមសារណាតបចុះថ្ងៃទី០១ កញ្ញាឆ្នាំ២០១២របស់ឈ្មោះ [redacted] លួម -[redacted]លន់ -[redacted] ធី ។

-បានស្ដាប់របាយការណ៍របស់ចៅក្រមទទួលបញ្ជា

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : រឿងក្តីនេះពុំប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈទេ អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះពិនិត្យ និងសំរេចចុះ។

<u>ដំណាក់ការទាញហេតុផលផាល់មាត់</u>

-ឈ្មោះ[redacted] ចឹក ជាដើមចោទ និង ជាម្ចាស់បណ្តឹងសាទុក្ខបាន ធ្វើសេចក្តីថ្លែងការណ៍ថាដី១រ៉ៃនេះជាកេរ្តិ៍របស់យាយចែកអោយខ្លួនថែរក្សាធ្វើស្រែរហូត ឯចុងចម្លើយមិនដែលធ្វើស្រែលើដីក្បែរៗខ្លួនទេ។ដី១រ៉ៃ(៤០គុណ៤០)ស្ថិតក្នុងទំហំដីខ្លួន២៨២០ម៉ែត្រការ៉េវីយ៉ាងណាខ្លួនពុំដឹងទេ។

-ឈ្មោះស៊ឹមលន់ជាចុងបណ្តឹងសាទុក្ខបានសេចក្តីថ្លែងការណ៍ថា :ដី១រ៉ៃ(៤០គុណ៤០)កន្លងមកដើមចោទថាខ្ចីបង្កបង្កើនផលទេក្រោយមកបែរជាទាមទារយកថែមទៀតដើមចោទមានដី៦រ៉ៃហើយ។ដីម្តាយខ្លួនមាន១៥រ៉ៃ ដើមចោទយក៦រ៉ៃធ្វើប្លង់ហើយ សូមតុលាការពិចារណា ទុកដីទំនាស់ចែកអោយប្អូនៗផងព្រោះក្រណាស់។

-លោក[redacted].សុគន្ធមេធាវី តំណាងដោយអណត្តិអោយដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា:ដីទំហំ២៨២០ម៉ែត្រការ៉េនិង ដី១រ៉ៃជាដីតែមួយកន្លែងទេដើមចោទបានកាន់កាប់បន្តមរតកពីម្តាយមកដល់សព្វថ្ងៃបើពិនិត្យពីកិរិយាកាន់កាប់មានរយៈកាលជិត៣០ឆ្នាំហើយដីទំនាស់ជាចំណែករបស់ដើមចោទនិងចុងចម្លើយតែតុលាការខេត្តនិងសាលាឧទ្ធរណ៍សំរេចប្រគល់ដីអោយតែចុងចម្លើយមិនត្រឹមត្រូវ។សុំបង្វិលសំណុំរឿងអោយសាលាឧទ្ធរណ៍ជំនុំជំរះឡើងវិញ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមទទួលបញ្ហា
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់គូភាគីនិងសេចក្តីថ្លែងការណ៍មេធាវីតំណាងដោយអណត្តិរបស់ដើមចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## <u>តុលាការកំពូល</u>

-<u>យល់ឃើញថា</u> : បណ្តឹងសាទុក្ខលេខ១២៨ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១២ របស់លោក[redacted].សុគន្ធ មេធាវីតំណាងដោយអណត្តអោយដើមចោទឈ្មោះ[redacted].ចឹក ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា និង មាត្រា២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-<u>យល់ឃើញថា</u>:ការដែលសាលាឧទ្ធរណ៍ក៏ដូចជាសាលាដំបូងផងដែរដែលបានសំរេចច្រានចោលការទាមទាររបស់ដើមចោទតែបានសំរេចប្រគល់ដីចំការទំហំ ២៨២០ ម៉ែត្រការ៉េ អោយទៅសហាចុងចម្លើយទាំងបីនាក់ដោយសំអាងថា គូភាគីជាបងប្អូនបង្កើតនឹងគ្នា ហើយដើមចោទជាបងបានទទួលដីជាកេរ្តិ៍របស់ម្តាយជាច្រើនមកហើយ ហេតុនេះដីទំហំ ២៨២០ម៉ែត្រការ៉េនេះដែល ជាដី

មរតករបស់ម្តាយគូភាគីត្រូវបានជាចំណែករបស សហចុងចម្លើយទាំងបីនាក់នោះគឺពុំទាន់មានមូលដ្ឋានច្បាស់លាស់នៅឡើយទេ ព្រោះថាដើមចោទប្តឹងទាមទារដីទំហំ ៤០គុណ៤០ម៉ែត្រ ឯសហចុងចម្លើយប្តឹងតបទាមទារសិទ្ធិលើដីទំហំ ២៨២០ម៉ែត្រការ៉េ ករណីគម្បីមានគំនូសប្លង់បង្ហាញអំពីទំហំនិងទីតាំងនដីទំនាស់អោយបានច្បាស់លាស់ជាមុន មុននិងធ្វើការសំរេចសេចក្តី។

-យល់ឃើញថា: សាលដីការដ្ឋប្បវេណីលេខ ០៤"ក្រពាស" ចុះថ្ងៃទី២៩ខែកុម្ភៈឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ដែលសម្រេចមកនេះមិនមានលក្ខណៈត្រឹមត្រូវឡើយ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ១២៨ ចុះថ្ងៃទី១៩ ខែ មេសា ឆ្នាំ២០១២ របស់ដើមចោទ។

២-បដិសេធសាលដីការដ្ឋប្បវេណីលេខ ០៤"ក្រពាស" ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ១២៥ ចុះថ្ងៃទី២៥ ខែ មិថុនាឆ្នាំ២០១២របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះសារជាថ្មី។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

៥-សាលដីកាបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១៣ខែវិច្ឆិកា ឆ្នាំ២០១២ និងប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែ វិច្ឆិកា ឆ្នាំ២០១២។

-ឯកឧត្តម [redacted] ប្រធាន

-លោក [redacted] ចៅក្រម

-លោក [redacted] ចៅក្រម

-លោក [redacted] ចៅក្រម

-លោក [redacted] ចៅក្រម

-លោក [redacted] ក្រឡាបញ្ជី

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ភ្នំពេញ ថ្ងៃទី០១ ខែមករា ឆ្នាំ ២០១៣

ក្រឡាបញ្ជី

[redacted]

បានឃើញ

ភ្នំពេញ ថ្ងៃទី០[illegible] ខែមករា ឆ្នាំ ២០១៣

ប្រធាន

[redacted]





២០៧

207